# ខរបុត្តជាតក



**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

*រៀបរៀងដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**កុល ផេង**

**ព.ស. ២៥៦៤**

# ខរបុត្តជាតក

រៀបរៀងដោយ

បណ្ឌិត **គុល ផេង**

សីល សមាធិ បញ្ញា

**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

**ព.ស. ២៥៦៤**

| | |
|---|---|
| ឈ្មោះសៀវភៅ | **ខរបុត្តជាតក** |
| រៀបរៀងដោយ | បណ្ឌិត **គុល ផេង** |
| | ប្រធានពុទ្ធិកបណ្ឌិតសភា<br>នៃសាកលវិទ្យាល័យ<br>បញ្ញាសាស្ត្រកម្ពុជា |
| ទីតាំងធ្វើ | ពុទ្ធិកបណ្ឌិតសភា |
| ការផ្សាយ | របស់ពុទ្ធិកបណ្ឌិតសភា |
| រក្សាសិទ្ធិ | ពុទ្ធិកបណ្ឌិតសភា |
| កាលបរិច្ឆេទ | ថ្ងៃសុក្រ ៨ កើត ខែជេស្ឋ<br>ឆ្នាំជូត ទោស័ក ព.ស.<br>២៥៦៤ ច.ល. ១៣៨២<br>ម.ស. ១៩៤២<br>ត្រូវនឹងថ្ងៃទី ២៩ ខែ<br>ឧសភា គ.ស. ២០២០ |

# ខរបុត្តជាតក

## បុព្វនិទាន

ព្រះបរមសាស្ដាចារ្យ កាលស្ដេចគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុដែលត្រូវភរិយាចាស់ (ភរិយាកាលនៅគ្រហស្ថ) លួងលោម បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា សច្ចំ កិរេវមាហំសុ ដូច្នេះជាដើម ។

## បច្ចុប្បន្ននិទាន

ព្រះសាស្ដាត្រាស់សួរភិក្ខុនោះថា "ម្នាលភិក្ខុ បានឮថា អ្នកអផ្សុកចង់សឹក ពិតមែនឬ ?" កាលភិក្ខុនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពិតមែន" ។ ព្រះបរមគ្រូសួរទៀតថា "អ្នកអផ្សុកចង់

*សឹក ព្រោះហេតុអ្វី ?" កាលភិក្ខុនោះ ទូលថា "បពិត្រព្រះអង្គ ព្រោះភរិយាចាស់" ។ ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុ ស្ត្រីនេះបានធ្វើនូវអំពើដែលមិនជាប្រយោជន៍ដល់អ្នកតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ សូម្បីក្នុងកាលមុន អ្នកអាស្រ័យស្ត្រីនេះ ត្រូវចូលទៅកាន់ភ្លើង ប៉ុន្តែអាស្រ័យបណ្ឌិតទើបបានជីវិត" លុះត្រាស់ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីត មកសម្តែងដូចតទៅ ។*

## អតីតនិទាន

*ក្នុងអតីតកាល កាលព្រះរាជាទ្រង់ព្រះនាមថា* **សេនកៈ** *គ្រងរាជសម្បត្តិនៅក្នុងនគរពារាណសី ។ ព្រះបរមពោធិសត្វជាព្រះឥន្ទ្រាធិរាជ ។*

កាលនោះ ព្រះបាទសេនកៈ ទ្រង់មានសេចក្ដីស្រឡាញ់រាប់អាននាគរាជមួយជាមិត្រ ។ បានឮមកថា នាគរាជនោះចេញអំពីពិភពនាគ ត្រាច់ទៅរកចំណីលើគោក ។ ពេលនោះ ក្មេងអ្នកស្រុកឃើញនាគហើយប្រាប់គ្នាថា "នេះជាពស់" ហើយនាំគ្នាយកដុំដីនិងកំណាត់ឈើជាដើមវាយ ។ ព្រះរាជាទ្រង់យាងកំសាន្តក្នុងព្រះរាជឧទ្យាន បានទតឃើញហើយ ក៏ទ្រង់ត្រាស់សួរថា "តើក្មេង ៗ ទាំងនោះធ្វើអ្វី?" ទ្រង់ជ្រាបថា "គេនាំគ្នាវាយពស់មួយ" ទើបត្រាស់ហាមថា "ពួកឯងកុំសម្លាប់វា ចូរឱ្យវាលូនទៅចុះ" ហើយទ្រង់ឱ្យនាគរាជនោះគេចទៅ ។ នាគរាជបានជីវិតហើយ បានទៅកាន់ឋាន**បាតាល**

*កាន់យករតនៈជាច្រើន ហើយចូលទៅកាន់ក្រឡាបន្ទំរបស់ព្រះរាជា ក្នុងវេលាកណ្ដាលរាត្រី ថ្វាយរតនៈទាំងនោះ ហើយទូលថា "បពិត្រមហារាជទូលព្រះបង្គំអាស្រ័យព្រះអង្គ ទើបបានជីវិត" ហើយបានចងមិត្តភាពនឹងព្រះរាជា ដូច្នេះហើយតែងតែទៅគាល់ព្រះរាជារឿយៗ ។ នាគរាជនោះបានតែងតាំងនាង***នាគមាណវិកា** (នាគញី) *ដែលមិនឆ្អែតក្នុងកាមគុណមួយរូប ក្នុងចំណោមនាងនាគមាណវិកាទាំងឡាយរបស់ខ្លួន ទុកជាប្រចាំក្នុងរាជដំណាក់ដើម្បីប្រយោជន៍ដល់ការរក្សាព្រះរាជា ។ ស្ដេចនាគរាជទូលថា "បពិត្រព្រះសម្មតិទេព កាលណាព្រះអង្គមិនឃើញនាងនាគ-*

*មាណវិកានេះ កាលនោះព្រះអង្គគប្បីរាយមន្តបទនេះ" ហើយបានថ្វាយមន្តមួយបទដល់ព្រះរាជា ។*

*ថ្ងៃមួយ ព្រះរាជាយាងទៅកាន់រាជឧទ្យានទ្រង់លេង**ឧទកកីឡា** (លេងទឹក) ក្នុងស្រះបោក្ខរណី ជាមួយនឹងនាងនាគមាណវិកា ។ នាងនាគមាណវិកាឃើញពស់ទឹកមួយ ក៏លះបង់អត្តភាពរបស់ខ្លួន (ក្លែងខ្លួនជាពស់) ទៅសេពអសទ្ធម្ម (សេពមេថុនធម្ម) ជាមួយនឹងពស់ទឹកនោះ ។ ព្រះរាជាកាលមិនឃើញនាងនាគមាណវិកានោះ ទ្រង់សង្ស័យថា "នាងទៅណាហ្ន៎" ទើបទ្រង់រាយមន្តហើយបានឃើញនាងនាគមាណវិកាកំពុងធ្វើអនាចារ ក៏ទ្រង់វាយដោយបន្ទះឫស្សី ។ នាងនាគ-*

មាណវិកាក្រោធក៏ចេញអំពីព្រះរាជឧទ្យាននោះ ទៅកាន់ពិភពនាគ ត្រូវស្តេចនាគរាជសួរថា "ហេតុដូចម្តេចបានជានាងមក" នាងទូលថា "សម្ងាញ់របស់ព្រះអង្គវាយខ្ញុំម្ចាស់ ដែលមិនធ្វើតាមពាក្យរបស់ខ្លួន" រួចនាងបង្ហាញស្នាមរបួសឱ្យមើល ។ នាគរាជមិនដឹងរឿងតាមសេចក្តីពិត ទើបហៅនាគកំលោះ ៤ នាក់មក បញ្ជូនទៅដោយព្រះតម្រាស់ថា "អ្នកទាំងឡាយចូរទៅ ចូរនាំគ្នាចូលទៅកាន់ក្រឡាបន្ទំរបស់ព្រះបាទសេនកៈ ហើយកម្ចាត់ព្រះរាជានោះដោយខ្យល់ច្រមុះ ឱ្យដូចជាអង្កាមចុះ" ។ នាគកំលោះទាំងនោះនាំគ្នាទៅហើយ បានចូលទៅកាន់បន្ទប់ ក្នុងវេលាដែលព្រះរាជាទ្រង់ផ្ទំ

នៅលើសយនៈដ៏មានសិរី ។ នៅពេលដែលនាគកំលោះទាំងនោះ ចូលទៅនោះឯង ព្រះរាជាបានត្រាស់សួរព្រះទេវីថា "ម្នាលនាងដ៏ចម្រើន នាងដឹងនាងនាគមាណវិកា ទៅណាទេ" ។ ព្រះទេវីទូលថា "ខ្ញុំម្ចាស់មិនដឹងទេ" ។ ព្រះរាជាទ្រង់ត្រាស់ថា "ថ្ងៃនេះ នាងនាគមាណវិកានោះ បានលះបង់អត្ត-ភាពរបស់ខ្លួន ហើយប្រព្រឹត្តអនាចារជាមួយពស់ទឹកមួយ ក្នុងពេលលេងទឹកស្រះបោក្ខរណីរបស់យើង ពេលនោះ យើងបានយកបន្ទះឫស្សីវាយនាង កុំឱ្យនាងធ្វើយ៉ាងនោះទៀត នាងប្រាកដទៅកាន់ពិភពនាគ ប្រាប់អ្វីដទៃ ដល់សម្លាញ់របស់យើង ហើយទម្លាយមិត្តភាពរវាងយើងនឹង

*សម្លាញ់របស់យើង ភ័យនឹងកើតឡើងដល់យើង មិនខានឡើយ” ។ នាគកំលោះទាំងនោះបានស្តាប់ដូច្នោះហើយ ក៏នាំគ្នាត្រឡប់ចេញអំពីរាជដំណាក់នោះ ហើយទៅកាន់ពិភពនាគ ទូលរឿងនោះចំពោះនាគរាជ ។ នាគរាជក៏សង្វេគហើយ បានយាងទៅកាន់រាជដំណាក់របស់ព្រះបាទសេនកៈ ទូលឱ្យទ្រង់ជ្រាបនូវរឿងនោះ និងសូមទោសព្រះអង្គ ហើយបានថ្វាយមន្តឈ្មោះ* ***សព្វរុតជាននមន្ត*** *(មន្តដែលអាចឲ្យដឹងសំឡេងសត្វគ្រប់ប្រភេទ) ដោយគិតថា “នេះជាទណ្ឌកម្មរបស់យើង” ហើយទូលថា “បពិត្រមហារាជ មន្តនេះមានតម្លៃណាស់ ប្រសិនបើព្រះអង្គប្រទានមន្តនេះដល់អ្នកដទៃ*

លុះទ្រង់ប្រទានហើយ ព្រះអង្គត្រូវចូលគំនរភ្លើង ឱ្យសុគត" ។ ព្រះរាជាទ្រង់ទទួលពាក្យថា "ប្រពៃហើយ" ។ តាំងពីពេលនោះមក សូម្បីតែសំឡេងស្រមោចក្រហម ក៏ទ្រង់ជ្រាបដែរ ។

ថ្ងៃមួយ កាលព្រះអង្គទ្រង់គង់ក្នុងព្រះរោងសោយ**ខាទនីយៈ**និងទឹកឃ្មុំ ទឹកអំពៅ ។ ទឹកឃ្មុំទឹកអំពៅមួយដំណក់ និងនំមួយចំណិត ធ្លាក់ទៅលើដី ស្រមោចក្រហមមួយឃើញដំណក់ទឹកឃ្មុំជាដើមនោះហើយ ស្រែកប្រាប់គ្នាថា "ពាងទឹកឃ្មុំរបស់ស្ដេចបែកនៅក្នុងព្រះរោង ទាំងឆ្នាំងទឹកអំពៅ និងឆ្នាំងនំក្រឡាប់ហើយ អ្នកទាំងឡាយចូរនាំគ្នាផឹកទឹកឃ្មុំ ទឹកអំពៅ និងស៊ីនំ" ។ ព្រះរាជា

ទ្រង់ព្រះសណ្តាប់នូវសំឡេងស្រែកប្រាប់គ្នារបស់ស្រមោចក្រហមហើយ ទ្រង់សើចយ៉ាងសប្បាយរីករាយ ។ ព្រះទេវីដែលគង់នៅជិតព្រះរាជានោះមានព្រះតម្រិះថា "ព្រះរាជាទ្រង់ឃើញអ្វី ទើបទ្រង់សើច" ។ កាលព្រះរាជាសោយក្រយាហារនិងទ្រង់ស្រង់ព្រះកាយហើយ ទ្រង់គង់លើរាជ-បល្ល័ង្ក មានរុយឈ្មោលជាស្វាមីនិយាយនឹងរុយញីមួយថា "តោះអូនសម្លាញ់ ពួកយើងនឹងអភិរម្យគ្នាដោយសេចក្តីត្រេកអរដោយអំណាចកិលេស" ។ ពេលនោះរុយញីនិយាយនឹងរុយឈ្មោលនោះថា "អត់ទ្រាំបន្តិចសិនបង ពេលនេះអ្នកបម្រើនឹងនាំគ្រឿងក្រអូប មកថ្វាយព្រះរាជា កាលព្រះអង្គទ្រង់

លាបគ្រឿងក្រអូបនោះ កម្ទេចគ្រឿងក្រអូបនឹង
ធ្លាក់ចុះទៀបបាទមូល ពេលនោះអូននឹងវែងឆាប
នៅទីនោះហើយនឹងមានក្លិនក្រអូប បន្ទាប់មក ចាំ
យើងនឹងដេកត្រេកត្រអាលគ្នាលើខ្នងព្រះរាជា" ។
ព្រះរាជាទ្រង់សណ្ដាប់នូវសំឡេងសូម្បីនោះហើយ
ក៏ទ្រង់សើច ( ហាស ! ហាស ! ) ។ ចំណែកព្រះ
ទេវីក៏ទ្រង់ព្រះតម្រិះទៀតថា ព្រះរាជាទ្រង់ឃើញ
អ្វីហ្ន៎ ទើបទ្រង់សើច ។ ពេលព្រះរាជាទ្រង់សោយ
ព្រះក្រយាហារក្នុងវេលាល្ងាច គ្រាប់បាយមួយ
គ្រាប់ធ្លាក់ទៅលើដី ស្រមោចក្រហមទាំងឡាយ ក៏
ស្រែកប្រាប់គ្នាថា "ឆ្នាំងព្រះក្រយាហារ ក្នុងរាជ-
ត្រកូលបែកហើយ អ្នកទាំងឡាយចូរនាំគ្នាទៅ

បរិភោគកត្តាហារ" ។ ព្រះរាជាលុះទ្រង់បាន
សណ្ដាប់នូវពាក្យនោះហើយ ក៏ទ្រង់សើចទៀត ។
ចំណែកព្រះទេវី ទ្រង់កាន់វែកមាសអង្គាសព្រះ
រាជា ក៏ទ្រង់ព្រះវិតក្កៈថា ព្រះរាជាទ្រង់ទតឃើញ
អ្វីហ្ន៎ ទើបទ្រង់សើច ។

ពេលព្រះនាងឡើងកាន់ក្រឡាបន្ទំជាមួយ
ព្រះរាជា ព្រះនាងក៏ទូលសួរថា "បពិត្រព្រះសម្មតិ
ទេព មានរឿងអ្វី ទើបព្រះអង្គទ្រង់សើច" ។ ព្រះ
រាជាត្រាស់ថា "នឹងមានប្រយោជន៍អ្វីដល់នាង
ព្រោះហេតុដែលយើងសើចនោះ" ព្រះរាជាត្រូវ
ព្រះទេវីរំអុក ឲ្យត្រាស់ប្រាប់រឿយៗ (ព្រះអង្គក៏
ដាច់ចិត្តប្រាប់រឿងពិតដល់ព្រះនាង) ។ លំដាប់

នោះ ព្រះនាងទូលព្រះរាជាថា "សូមព្រះអង្គទ្រង់ប្រទានមន្ត ដែលធ្វើឲ្យដឹងសំឡេងសត្វរបស់ព្រះអង្គដល់ខ្ញុំម្ចាស់ផង" សូម្បីត្រូវព្រះរាជាទ្រង់ហាមថា "មិនអាចឲ្យបានទេ" ក៏ព្រះនាងរំអុករឿយៗ ។ ព្រះរាជាក៏ទ្រង់ត្រាស់ថា "ប្រសិនបើយើងឲ្យមន្តនេះដល់នាងសោត យើងនឹងស្លាប់" ។ ព្រះទេវីទូលថា "បពិត្រព្រះសម្មតិទេព សូម្បីព្រះអង្គត្រូវអស់ព្រះជន្ម ក៏ត្រូវប្រទានឲ្យខ្ញុំម្ចាស់ដែរ" ។ ព្រះរាជាជាអ្នកធ្លាក់នៅក្នុងអំណាចនៃមាតុគ្រាម ទើបទ្រង់យល់ព្រមថា "ប្រពៃហើយ" ដោយទ្រង់កាត់ព្រះទ័យថា "យើងនឹងឲ្យមន្តដល់ព្រះទេវីហើយ

នឹងចូលគំនរភ្លើង” លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ស្ដេចចូលទៅកាន់ព្រះរាជឧទ្យានដោយរាជរថ ។

ខណៈនោះ សក្កទេវរាជទ្រង់ពិនិត្យមើលសត្វលោក ទ្រង់ឃើញហេតុការណ៍នោះ ហើយត្រិះរិះថា “ព្រះរាជាលួង់ខ្លៅអង្គនេះ អាស្រ័យមាតុគ្រាម យាងទៅដោយធ្វើទុកក្នុងព្រះទ័យថា ‘នឹងលោតចូលគំនរភ្លើង’ យើងនឹងឲ្យជីវិតដល់ព្រះរាជាអង្គនេះ” ហើយទ្រង់នាំយកអសុរកញ្ញាឈ្មោះ**សុជា** មកកាន់ក្រុងពារាណសី ទ្រង់ធ្វើនាងសុជា (ឲ្យនិម្មិតខ្លួន) ជាពពែញីមួយ ព្រះអង្គឯង (និម្មិត) ជាពពែឈ្មោល ហើយទ្រង់អធិដ្ឋានថា “សូមកុំឲ្យមហាជនឃើញ” ហើយបាននៅខាងមុខ

រាជរថ ។ ព្រះរាជា និងសេះដែលទឹមរថប៉ុណ្ណោះ បានឃើញពពែនោះ អ្នកដទៃមិនឃើញឡើយ ។ ពពែឈ្មោលសម្តែងអាការៈសេពមេថុននឹងពពែញី នៅខាងមុខរថ ដើម្បីនឹងសាងរឿងរ៉ាវឲ្យកើតឡើង ។ សេះដែលទឹមរថឃើញពពែនោះ ក៏និយាយថា "អាសម្លាញ់ពពែអើយ កាលមុន ពួកយើង 'បានឮគេតំណាលថា ពួកពពែជាសត្វល្ងង់មិនចេះអៀនខ្មាស' តែមិនដែលឃើញរឿងនោះទេ ប៉ុន្តែឯងប្រព្រឹត្តអនាចារដែលត្រូវធ្វើក្នុងទីកំបាំងដែលជាកន្លែងបិទបាំង នៅចំពោះមុខពួកយើងមានប្រមាណប៉ុណ្ណោះដែលកំពុងមើល ឯងមិនអៀនខ្មាសគេទេ ពាក្យដែលពួកយើងបានឮពី

មុនមកនោះ សមនឹងហេតុការណ៍ ដែលបាន ឃើញនេះឯង រួចសេះក៏ពោលគាថាទី ១ ថា

**សច្ចំ កិរេវ មាហំសុ វស្តំ ពាលោតិ បណ្ឌិតា**
**បស្ស ពាលោ រហោកម្មំ អាវិកុព្វំ ន ពុជ្ឈតិ។**

ឮថា បណ្ឌិតទាំងឡាយ បានពោលនូវសត្វពពែ ថាជាសត្វពាលដោយពិត អ្នកចូរមើលចុះ សត្វពាលមិនដឹងនូវអំពើ ដែលគួរធ្វើក្នុងទីកំបាំង ទៅធ្វើក្នុងទីវាល ។

*បណ្ដាបទទាំងនោះ បទថា វស្តំ បានដល់ពពែ ។*

*បទថា* **បណ្ឌិតា** *សេចក្ដីថា អ្នកដល់ព្រមដោយញាណទាំងឡាយបានពោលថា ពពែជាសត្វពាលល្ងង់ខ្លៅ បានឮថា ពោលពាក្យពិត ។*

*បទថា បស្ស ជាពាក្យអាលបនៈ សេចក្ដីថា ចូរមើលចុះ ។*

*បទថា ន ពុជ្ឈតិ សេចក្ដីថា មិនដឹងថា ការធ្វើយ៉ាងនេះ មិនគួរ ។*

*ពពែបានស្ដាប់ពាក្យនោះហើយ ទើបពោល ២ គាថា ថា*

**ត្វំ ខោបិ សម្ម ពាលោសិ ខរបុត្ត វិជានហិ**
**រជ្ជុយា ហិ បរិក្ខិត្តោ វង្កោដ្ឋោ ឱហិតោមុខោ។**

*ម្នាលសម្លាញ់ អ្នកទេឬ ជាសត្វពាល ម្នាលខរបុត្ត អ្នកចូរដឹងចុះ អ្នកជាសត្វដែលត្រូវគេរួបរឹតដោយខ្សែ មានបបូរមាត់វៀច មានមុខឱនចុះ ។*

**អបរម្បិ សម្ម តេ ពាល្យំ យោ មុត្តោ ន បលាយសិ**
**សោ ច ពាលតរោ សម្ម យំ ត្វំ វហាតិ សេនកំ។**

ម្នាលសម្លាញ់ អ្នកណាបានរួចចេញ (អំពីរថ) មិនរត់ទៅ អ្នកនោះ ពេញជាពាលទៅទៀត ម្នាលសម្លាញ់ អ្នកនាំនូវស្តេចសេនកៈណា ស្តេចសេនកៈនោះ ចាត់ជាមនុស្សពាលបំផុត ។

*បណ្តាបទទាំងនោះ បទថា **ត្វំ ខោបិ សម្ម** សេចក្តីថា សម្លាញ់សិន្ធវៈអើយ អ្នកល្ងង់ជាងខ្ញុំឆ្ងាយណាស់ ។*

*បទថា **ខរបុត្ត** សេចក្តីថា បានឮថា សេះនោះជាសត្វកើតអំពីលា ព្រោះហេតុនោះ ទើបពពោលនឹងសេះនោះយ៉ាងនេះ (ម្នាលកូនលា) ។*

*បទថា **វិជានហិ** សេចក្តីថា អ្នកចូរដឹងចុះថា អ្នកនោះឯងល្ងង់ ។*

*បទថា* **បរិក្ខិត្តោ** *សេចក្ដីថា អ្នកត្រូវគេរឹតក ទីងទីម ។*

*បទថា* **វេឌ្ឍោវេឌ្ឍោ** *បានដល់ មានបបូរមាត់ វៀច ។*

*បទថា* **ឱហិតោមុខោ** *បានដល់ មានមាត់ ត្រូវខ្សែចងបិទមាត់ ។*

*បទថា* **យោ មុត្តោ ន បលាយសិ** *សេចក្ដីថា ការដែលអ្នករួចចេញអំពីរថ ហើយមិនរត់ចូលព្រៃ ក្នុងពេលដែលរួចផុតហើយ មិនរត់គេចទៅ នោះ ជាបុគ្គលល្ងង់ខ្លៅណាស់ ។*

*បទថា សោ ច ពាលតរោ សេចក្តីថា ព្រះបាទសេនកៈដែលអ្នកនាំទៅនោះ ពាលជាង អ្នកទៅទៀត ។*

*ព្រះរាជាដឹងពាក្យរបស់សត្វទាំង ២ នោះ ព្រោះហេតុនោះ កាលទ្រង់សណ្តាប់នូវពាក្យនោះ តទៅទៀត ទើបទ្រង់បញ្ជាឲ្យបររថតិច ៗ ។ ចំណែកសេះសិន្ធវៈ លុះបានស្តាប់ពាក្យរបស់ ពពែហើយ ទើបពោលគាថាទី ៤ ថា*

**យំ នុ សម្ម អហំ ពាលោ**

**អជរាជ វិជានហិ**

**អថ កេន សេនកោ ពាលោ**

**តំ មេ អក្ខាហិ បុច្ឆិតោ ។**

ម្នាលសម្លាញ់ បើខ្ញុំជាសត្វពាល ដោយហេតុណា ម្នាលអជរាជ អ្នកចូរដឹងនូវហេតុនោះចុះ តែថា ស្តេចសេនកៈជាមនុស្សពាល ដោយហេតុដូចម្តេច អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់ហេតុនោះ ។

*បណ្តាបទទាំងនោះ បទថា យំ ជាបច្ចត្តវចនៈ ប្រើក្នុងអត្ថករណៈ (បឋមាវិភត្តិប្រើក្នុងអត្ថតតិយាវិភត្តិ) ។*

*បទថា ឧ ជានិបាត ប្រើក្នុងអត្ថថា តាមស្តាប់ ។*

មានពាក្យអធិប្បាយថា ម្នាលសម្លាញ់អជរាជ ខ្ញុំល្ងង់ព្រោះហេតុគឺភាពជាសត្វតិរច្ឆានឯណា អ្នកដឹងនូវហេតុនោះ រឿងនេះអ្នកអាចដឹង

បាន ព្រោះថា ខ្ញុំជាបុគ្គលពាលល្ងង់ខ្លៅ ព្រោះជាសត្វតិរច្ឆាននោះឯង ព្រោះហេតុដូច្នោះ អ្នកកាលពោលថា ម្នាលកូនលាជាដើមនឹងខ្ញុំ (ក៏ឈ្មោះថា) ពោលត្រូវពោលប្រសើរហើយ, តែអ្នកពោលថា ព្រះរាជាសេនកៈនេះជាមនុស្សពាល ព្រោះហេតុអ្វី អ្នកត្រូវខ្ញុំសួរហើយ ចូរប្រាប់នូវហេតុនោះដល់ខ្ញុំ ៗ

ពពែស្តាប់ពាក្យនោះហើយ កាលនឹងប្រាប់នូវហេតុនោះ ទើបពោលគាថាទី ៥ ថា

**ឧត្តមត្ថំ លភិត្វាន ភរិយាយ យោ បទស្សតិ**
**តេន ជហិស្សតត្តានំ សា ចេវស្ស ន ហេស្សតិ។**

**បុគ្គលណា បាននូវមន្តជាប្រយោជន៍ដ៏ឧត្តម ហើយប្រគល់ឲ្យប្រពន្ធ ( បុគ្គលនោះ ) នឹងលះបង់នូវខ្លួន ដោយការឲ្យមន្តនោះ ទាំងប្រពន្ធនោះ នឹងមិនមានដល់បុគ្គលនោះឡើយ ។**

*បណ្ដាបទទាំងនោះ បទថា* ***ឧត្តមត្ថំ*** *បាន ដល់* ***សព្វរុតជាននមន្ត*** *(មន្តជាហេតុឲ្យដឹងសំឡេងសត្វគ្រប់ប្រភេទ) ។*

*បទថា* ***តេន*** *សេចក្ដីថា ព្រោះហេតុពោល គឺការឲ្យមន្តដល់ភរិយានោះ បុគ្គលនោះលុះឲ្យមន្តនោះហើយ ក៏នឹងលះបង់ជីវិត ដោយការលោតចូលគំនរភ្លើង បុគ្គលនោះនឹងមិនមានភរិយានោះ ព្រោះហេតុនោះ បុគ្គលនោះគឺ*

*ព្រះបាទសេនកៈ អ្នកមិនអាចរក្សាយស ដែលបានហើយទុកបាន ទើបជាបុគ្គលល្ងង់ខ្លៅជាងអ្នកទៅទៀត ។*

ព្រះរាជា លុះទ្រង់បានសណ្តាប់នូវពាក្យរបស់ពពែនោះហើយ ក៏ទ្រង់ត្រាស់ថា ម្នាលអជរាជអើយ អ្នកកាលធ្វើសេចក្តីសួស្តីឲ្យយើង អ្នកនឹងធ្វើនូវអំពើនោះ, សូមអ្នកប្រាប់អំពើដែលគួរធ្វើដល់យើងជាដំបូង ។ ពេលនោះ អជរាជក៏ទូលព្រះរាជាថា បពិត្រមហារាជ មិនមានអ្នកដទៃជាទីស្រឡាញ់នៃសត្វទាំងឡាយ ឲ្យក្រៃលែងជាងខ្លួនទេ បុគ្គលមិនគួរធ្វើខ្លួនឲ្យវិនាសទេ មិនគួរលះបង់យសដែលបានហើយ ព្រោះអាស្រ័យ

របស់ដែលជាទីស្រឡាញ់នោះទេ ដូច្នេះហើយ

ទើបពោលគាថាទី ៦ ថា

ន វេ បិយម្មេតិ ជនិន្ទ តាទិសោ

អត្តំ និរំកត្វា បិយានិ សេវតិ

អត្តាវ សេយ្យោ បរមា ច សេយ្យោ

លព្ភា បិយា ឱចិតត្ថេន បច្ឆា ។

បពិត្រព្រះអង្គជាធំជាងជន បុគ្គលបែបនោះ

លះបង់ចោលនូវខ្លួន មិនសេពគប់នូវវត្ថុជាទី

ស្រឡាញ់ ដោយគិតថា ( វត្ថុនេះ ) ជាទីស្រឡាញ់

របស់អញ ខ្លួនឯងទើបប្រសើរជាងរបស់ដែល

ប្រសើរទៅទៀត ព្រោះបុរសដែលមានខ្លួនអប់រំ

*ហើយ គប្បីបាននូវជនជាទីស្រឡាញ់ ក្នុងកាលជាខាងក្រោយ ។*

កប្បីជ្រាបការវិនិច្ឆ័យក្នុងគាថានោះដូចតទៅ ៖

*បពិត្រព្រះអង្គជាធំជាងជន បុគ្គលអ្នកតាំងនៅក្នុងភាពដ៏ក្រៃលែងដោយយស ដូចព្រះអង្គលះបង់ការអាល័យខ្លួន គឺបោះបង់ខ្លួន មិនគប់រករបស់ដែលជាទីស្រឡាញ់ទាំងនោះថា វត្ថុនេះជាទីស្រឡាញ់របស់យើង ព្រោះអាស្រ័យស្ត្រី ដែលជាកណ្ណៈជាទីស្រឡាញ់ម្នាក់ ។ ព្រោះហេតុអ្វី ? (ព្រោះថា)* ***អត្តាវ សេយ្យោ បរមា ច សេយ្យោ*** *ខ្លួនឯងប្រសើរជាងមនុស្សដែលប្រសើរយ៉ាងក្រៃ-*

ផែង អធិប្បាយថា ព្រោះខ្លួនឯងប្រសើរគឺលើស ខ្ពស់ជាងវត្ថុដែលប្រសើរដ៏ក្រៃលែង គឺជាភណ្ឌៈ ដែលជាទីស្រឡាញ់ជាងវត្ថុដទៃ ដ៏កំពូលគឺខ្ពស់ បំផុត ដោយការគុណនឹងមួយរយ មួយពាន់ ។ ធម្មតាថាបុគ្គលដែលបានសន្សំបុណ្យទុកហើយ គឺ មានខ្លួនចម្រើនហើយ អាចបានស្ត្រីដែលជាទី ស្រឡាញ់ ក្នុងកាលជាខាងក្រោយ បុគ្គលមិនគួរ ធ្វើខ្លួនឲ្យវិនាសទៅ ព្រោះហេតុតែស្ត្រី ដែលជាទី ស្រឡាញ់នោះទេ ។

ព្រះមហាសត្វថ្វាយឱវាទដល់ព្រះរាជា យ៉ាងនេះហើយ ។ ព្រះរាជាទ្រង់ពេញព្រះទ័យ

ហើយត្រាស់សួរថា ម្នាលអជរាជ អ្នកមកអំពីទីណា ?

សក្កទេវរាជត្រាស់តបថា បពិត្រមហារាជ យើងគឺសក្កទេវរាជ មកដោយការអនុគ្រោះមហាបពិត្រ ដើម្បីនឹងដោះមហាបពិត្រ ឲ្យផុតពីសេចក្ដីស្លាប់ ។

ព្រះរាជាត្រាស់ថា " បពិត្រទេវរាជ ទូលព្រះបង្គំ បានបញ្ចេញវាចាទៅហើយថា ទូលបង្គំនឹងឲ្យមន្តដល់ព្រះទេវី ពេលនេះទូលព្រះបង្គំនឹងធ្វើយ៉ាងណា" ?

សក្កត្រាស់ថា "បពិត្រមហារាជ កិច្ចដោយការវិនាសនឹងមិនមានដល់អ្នកទាំង ២ បើមហា-

បពិត្រ ពោលថា ឧបចារនៃមន្តនេះ មាន” ហើយឲ្យមនុស្សម្នាក់វាយព្រះទេវី ២-៣ រំពាត់ ដោយឧបាយយ៉ាងនេះ ព្រះទេវីនឹងមិនរៀនមន្តទេ ។

ព្រះរាជាទ្រង់ទទួលទេវតម្រាស់ថា “ប្រពៃហើយ” ។ ព្រះមហាសត្វថ្វាយឱវាទព្រះរាជាហើយ ស្ដេចទៅកាន់ឋានរបស់ព្រះអង្គវិញ ។ ព្រះរាជាទ្រង់យាងទៅដល់ព្រះរាជឧទ្យានហើយត្រាស់បញ្ជាឲ្យយាងព្រះទេវីមក ហើយទ្រង់ត្រាស់សួរថា “ម្នាលនាងដ៏ចម្រើន នាងនឹងរៀនមន្ត ពិតមែនឬ”?

ព្រះទេវីទូលថា “បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់នឹងរៀនពិតមែន” ។

ព្រះរាជាត្រាស់ថា "បើដូច្នោះ យើងនឹងធ្វើឧបចារៈនៃមន្ត" ។

ព្រះទេវីទូលថា "ឧបចារៈជាយ៉ាងណា" ?

ព្រះរាជាត្រាស់ថា "ត្រូវឲ្យគេវាយខ្នង ១០០ រំពាត់ ហើយនាងមិនត្រូវស្រែកទេ" ។

ព្រះទេវីទទួលព្រះរាជតម្រាស់ថា "សាធុ" ព្រោះតែព្រះនាងចង់បានមន្ត ។

ព្រះរាជាត្រាស់បញ្ជាឲ្យហៅអ្នកសម្លាប់ចោរ គឺពេជ្ឈឃាតមកហើយ ឲ្យយករំពាត់ខ្សែតី ទៅវាយទាំង ២ ខាង ។ ព្រះទេវីអត់ទ្រាំនឹងការវាយ ២-៣ ដងបាន តអំពីនោះទៅ ទ្រង់ស្រែកថា "ខ្ញុំម្ចាស់មិនត្រូវការមន្តទេ" ។ ពេលនោះ ព្រះរាជា

ទ្រង់ត្រាស់ទៅកាន់ព្រះទេវីថា "នាងប្រាថ្នារៀនមន្ត ដោយចង់ឲ្យយើងស្លាប់ឬ" ហើយទ្រង់ឲ្យពន្ធាត់ស្បែកខ្នង (ដែលរបក) ចោល ។ ចាប់ពីពេលនោះមក ព្រះទេវីក៏មិនហ៊ានសូមរៀនមន្តទៀតឡើយ ។

## ជាតកាវសាន

ព្រះបរមសាស្តា លុះទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ ទើបទ្រង់ប្រជុំជាតក ទីបំផុតនៃសច្ចធម៌ ភិក្ខុដែលអផ្សុកចង់សឹកនោះ បានសម្រេចសោតាបត្តិផល ។

- តទា រាជា ឧក្កណ្ឋិតភិក្ខុ អហោសិ

  *ព្រះរាជាក្នុងកាលនោះ បានមកជា ភិក្ខុ ដែលអផ្សុកចង់សឹកនេះឯង*

- ទេវី បុរាណទុតិយិកា *ព្រះរាជទេវី បាន មកជាភរិយាចាស់*

- អស្សោ សារិបុត្តោ *សេះជាព្រះសារីបុត្រ*

- សក្កោ បន អហមេវ អហោសិំ

  *ចំណែកសក្កទេវរាជ គឺ* ***តថាគត*** *នេះឯង។*

*ខរបុត្តជាតក ចប់ ៕*

(*ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ឆក្កនិបាត ខរបុត្តវគ្គ ខរបុត្តជាតក បិដកលេខ ៥៩ ទំព័រ ៥៤*)



ម្នាលសម្ងាញ់ អ្នកណាបានរួចចេញអំពីរថ
មិនរត់ទៅ អ្នកនោះពេញជាពាលទៅទៀត
ម្នាលសម្ងាញ់ អ្នកនាំនូវស្ដេចសេនកៈណា
ស្ដេចសេនកៈនោះចាត់ជាមនុស្សពាលបំផុត